«ថាម៉េច?»
តើរឿងនេះកើតឡើងយ៉ាងម៉េចបានទៅ? ទោះយ៉ាងណាមនុស្សដូចនាងក៏មិនសមណាថាមកលេងសើចកុហក ខ្ញុំលេង?
គិតបែបនេះ តែមិនបានសួរនាងទេ។
វត្តមាននាងនៅជិតបង្កើយជាអំណោយមួយធំហើយ ខ្ញុំទៅរវល់អីជាប្រធានបទផ្សេង?
ដំបូងចង់សម្ភាសន៍ចង់ស្គាល់នាង គិតថានាងជាមនុស្សHightណាស់ ពេលនេះវិញ អាការៈនាងមិនបានប្រកាន់ខ្លួនទេ  គឺដូចពាក្យចាស់ថា រកអុសប្រទះឈើងាប់។ នាងមកដល់ពិព័រណ៍នេះក្នុងនាមជាវិចិត្រករល្បី ហើយនាំមកជាមួយផងដែរ នូវប្រភេទគំនូរដ៏ស្រស់ស្អាត ថែមទាំងបង្ហាញនូវទឹកចិត្តដ៏សប្បុរស ភាពក្លៀវក្លាវរាងសរវៃ នេះទើបជាចំណាប់អារម្មណ៍ពិតរបស់ខ្ញុំ.....
«បើមិនប្រកាន់ទេ យើងដើរទៅសាលធំជាមួយគ្នា!»
នាងសម្លឹងមកខ្ញុំដោយទឹកមុខបារម្ភ តែនាងងក់ក្បាលយល់ព្រម....
«ចាំបន្តិចខ្ញុំចូលទៅយកម៉ាស៊ីនថត!»
មិនមែនជារឿងគួរឱ្យសង្ស័យទេ ដែលចិត្តកំលោះដូចខ្ញុំទោរទន់ទៅលើស្រីស្អាតដូចគេ ប៉ុន្តែក៏ជារឿងគួរឱ្យសោកស្តាយមនុស្សមានឋានៈតូចទាបមិនដឹងថារឿងនេះទៅមុខរបៀបណាឡើយ។ ទោះបីជាយ៉ាងណាឱកាសក្នុងដៃហើយ។ ខ្ញុំច្បូតទាញសក់រៀបរយ និងឆ្លៀតបាញ់ទឹកអប់មួយច្រូចស្រវាទាញកាម៉េរានិងកាបូបចេញទៅក្រៅវិញ មិនចង់ឱ្យស្រីស្អាតរង់ចាំយូរ។
នៅពេលបណ្តើរគ្នាឆ្ពោះទៅរកសាលពិព័រណខ្ញុំឆ្លៀតប្រាប់នាង៖
«ការពិតទៅ ខ្ញុំសុំពូបណ្ឌិតថា ចង់សម្ភាសន៍ខ្លួនឯង !»
«ខ្ញុំនេះ?»
«បាទ! តែគាត់មានប្រសាសន៍ថា ខ្លាចប៉ះពាល់ដល់ទឹកចិត្តភ្ញៀវ!»
«មិនអីទេ...ប៉ះពាល់អីទៅ! .... ប៉ុន្តែ.....គ្រាន់តែខ្ញុំមិនចូលចិត្តចេញមុខនៅលើកាសែតឬអីច្រើន!»
«អឺចឹង!,.....អូខេ ខ្ញុំគោរពការសម្រេចចិត្ត! ប៉ុន្តែ ខ្ញុំសង្ឃឹមថា ស្អែកឬខានស្អែក តរុណី នឹងផ្លាស់ប្តូរការសម្រេចចិត្តវិញ!»
នាងញញឹមងាកមកហាក់មិនខឹងទេដែលខ្ញុំហៅនាងចំឈ្មោះត្រង់ៗដូច្នេះ។
មកដល់សាលធំ ខ្ញុំនឹងនាងបែកគ្នាតាមភារកិច្ចរៀងៗ។ ទោះយ៉ាងណាដំបូងៗ ខ្ញុំឃើញនាងត្រូវបានស្វាគមន៍ដោយវិចិត្រករក្មេងចាស់ នានា ចំណែកឯ អ្នកចូលរួមទស្សនាវិញ ក៏ម្នាក់ៗតាមសម្លឹងនាងដោយស្រលាញ់ពេញចិត្តដែរ។
ដោយសារខ្ញុំមានភារកិច្ចចំពោះមុខក៏រវល់រៀងខ្លួនរួចក៏រវល់បាត់ លែងឃើញគ្នាមួយរយៈ។

កម្មវិធីបើកពិព័រណ៍«គំនូរទឹកប្រៃ» ចាប់ដំណើរការរហូតដល់ម៉ោង៩កន្លះ និងបន្តការលៀងអាហាររហូតជិតម៉ោង១២អធ្រាត្រហើយ ក៏នៅសេសសល់អ្នកមុខអ្នកការច្រើន ។
ខ្ញុំងងុយខ្លាំងមែនទែន ព្រោះតែអស់កម្លាំង ក្រោយការថតនឹងសរសេរអត្ថបទផុសបន្តបន្ទាប់។ ដោយដើរមកវិញតែឯងតម្រង់រកបន្ទប់ ប៉ះធាតុអាកាសកណ្តាលអធ្រាត្រដ៏ត្រជាក់ល្អផង ចិត្តនឹកឃើញតែរឿងគេង ខ្ញុំហាក់ដូចជាបំភ្លេចចោលប្រធានបទ« មនុស្សប្រុសឈាមពេញខ្លួន»កាលពីល្ងាច។
មុនពេលមកដល់បន្ទប់ ខ្លួនឯង ខ្ញុំក្រឡេកពីចម្ងាយឃើញសំណង់វីឡាចាស់មួយ ដែលមានតុបតែងភ្លើងមើលពីនេះទៅហាក់ផ្លូងៗ ដូចសម្រាប់ពួកបរទេសដែលមិនសូវចូលចិត្តចង្កៀងភ្លឺទេ គេខ្លាចប៉ះពាល់ភ្នែកគេ ពេលនេះខ្ញុំក៏នឹកឃើញឡើងវិញនូវពាក្យពេចន៍ភ័យព្រួយរបស់នាង។
«... តែក្រុមគំនូរស្រីៗគេឱ្យសម្រាកនៅសណ្ឋាគារមួយទៀត នៅជិតនេះដែរ គេថាសណ្ឋាគារប៉ុន្តែខ្ញុំមើលទៅដូចជាផ្ទះសំណាក់មានបន្ទប់ស៊ុបទ្រុបព័ទ្ធដោយព្រៃ»
«គេងមិនលក់ទេ! តែឮសូរមនុស្សប្រុសថ្ងូរឈឺចាប់! ឮរហូត....»
ខ្ញុំស្វាងនឹកឃើញគេ....លែងសូវងងុយហើយ។ គេនៅ ឯណា តើទៅដល់បន្ទប់ឬនៅ? ខ្ញុំគួរតែបានជូនគេទៅ។
គិតហើយខ្ញុំប្រុងបកក្រោយតាមរកគេសិនព្រោះមិនមានលេខទូរសព្ទ....
ស្រាប់តែ....ខ្ញុំដូចជាឮសូរអ្វីម្យ៉ាង នៅខាងស្តាំដៃ។ ដូចជាស្នូរជើងមនុស្សរត់?
បើថាដើរក៏ដើរញាប់ណាស់ដែរនិងមិនមែនមនុស្សតែម្នាក់ទេ។
កណ្តាលយប់ហើយ នោះជាច្រកដែលសាស្ត្រាចារ្យ ជា បណ្ឌិត បានហាមខ្ញុំមិនឱ្យធ្វើដំណើរកាត់ ។ ខ្ញុំមានអារម្មណ៍ថា មានមនុស្សធ្វើអ្វីម្យ៉ាងនៅទីនោះ ដោយមានច្រើនគ្នាទៀតផង។
ខ្ញុំគិតចុះឡើង មុនពេលសម្រេចចិត្តឈានទៅរកមើលប្រភពសូរសំឡេងជើង។
ដៃមិនទាន់មានពិលនៅឡើយ ខ្ញុំឈានយឺតៗនិងរក្សាលំនឹងស្រាលបំផុតខ្លាចគេដឹង។ មិនយូរជាងបីបួនដង្ហើមសោះ ក៏ប្រទះឃើញស្រមោលមនុស្សលើដី ។ ស្រមោលមកដល់មុនជាមនុស្ស២នាក់ក្រោយមកកើនចំនួនឡើង។
ដូចមានការសម្រេចចិត្តរហ័ស អ្វីដែលអាចធ្វើបានគឺខ្ញុំ ថយមកលាក់ខ្លួនក្នុងជ្រុងអាគារដ៏ងងឹតមួយ។ ទីនេះមានរបាំងថ្ម បើថាពួកគេចាំងពិលមកក៏ខ្ញុំនៅតែលឹបបំពួនបាន.....
ពិតណាស់ មនុស្សទាំងនោះរលេះរលាំងដើរមកដល់យ៉ាងញាប់ជើង។
ហើយខ្ញុំប្រឹងអត់ដង្ហើម អង្គុយសំងំនៅក្នុងភាពងងឹត អើតលបមើលពួកគេដោយក្តីសង្ស័យ។ អាចជាចោរមកលួចគំនូរ ឬអាចជាអ្វីតាមដែលនឹកឃើញសម្តីនាងបានប្រាប់ខ្ញុំថាមាន ប្រុសម្នាក់រងរបួសរត់មកផ្លូវដដែលនេះកាលពីព្រលប់?

ភ្លាមនោះក្នុងចំណោមអ្នកដើរខ្ញុំឃើញមានប្រុសបីនាក់ស្រីម្នាក់។ សុទ្ធតែឈានរហ័សរលះរលាំង
ក្រឡេកឆ្វេងស្តាំប្រុងប្រយ័ត្នខ្ពស់ណាស់ ដូចខ្លាចថា មានគេឃើញ។
ស្ត្រីម្នាក់នោះ ឱបអ្វីពេញដៃទាំងពីរចំណែកប្រុសៗមានកាន់ដំបងនិងពូថៅ។
«លឿនបន្តិច! ប្រយ័ត្នមានគេឃើញទៀត!»
នេះជាសំឡេងស្ត្រីម្នាក់នោះ ជាស្ត្រីវ័យចំណាស់ហើយតែដើរបានរហ័សណាស់។ សូម្បីតែកាត់តាម
កន្លែងខ្ញុំនៅ ពួកគេហាក់មិនបានចាប់អារម្មណ៍អ្វី ពិតជាស្លុងទៅក្នុងរឿងសំខាន់ណាផ្សេងមិនខាន។
ញាណម៉្យាងប្រាប់ខ្ញុំថា ពួកគេមកពីធ្វើអ្វីមួយមិនប្រក្រតីទេ។
អាការៈដើរយ៉ាងញាប់ ភ្នែកក្រឡេក ឆ្វេងស្តាំ អើតមើលមុខក្រោយ ដូចជាមានការប្រុងប្រយ័ត្នខ្លាំង
ប្រាកដជាបានធ្វើអ្វីមួយដែលមិនចង់ឱ្យមានអ្នកណាឃើញ? ខ្ញុំលឹបមុខសិន លែងសម្លឹង....
ខ្ញុំគួរនិយាយប្រាប់ តរុណីឬពូបណ្ឌិតទៅ?
ហើយក្រែងថា ម្តុំនោះមិនឱ្យទៅពេលយប់ ម៉េចក៏មានមនុស្សនាំគ្នាដើរកាត់? គិតហើយបន្តិច សម្រឹ
បជើងរត់ក៏ព្រួឆ្ងាយឡើងៗកាលណា ខ្ញុំងើបមុខសម្លឹងម្តងទៀត។ ពួកគេបានដើរហួសទីងងឹតទៅដល់
កន្លែងភ្លឺហើយ។
ក្រោមអំពូលភ្លឺនៃរបៀងអាគារខាងមុខ ខ្ញុំស្គាល់អ្នកដែលដើរចុងក្រោយគេ។ មើលតាមរយៈសម្លៀក
បំពាក់ ខោយារគូទពណ៌គគីឬនិងអាវឆ្នូតសេះបង្កង់ គាត់គឺជាមនុស្សម្នាក់ដែលខ្ញុំបានឃើញឈរ
និយាយជាមួយលោកសាស្ត្រាចារ្យ ជា បណ្ឌិតកាលពីព្រឹកមិញ។
ទំនាក់ទំនងពួកគេអាចជិតស្និទ្ធ ដោយសារគិតរំឭកឡើងវិញ តាំងពីពេលខ្ញុំមកដល់កម្មវិធីពិព័រណ៍នេះ
កាលណា រហូតដល់កម្មវិធីបើកកាលពីព្រលប់ ខ្ញុំក៏បានឃើញម្នាក់នោះដដែលនៅក្បែរៗពូជា បណ្ឌិត
ទធ្វើនេះនោះតាមគាត់បង្គាប់ និងជួនខ្សឹបខ្សៀវគ្នាចុះឡើងមិនទំនេរទេ។
ខ្ញុំរត់បកទៅកាន់កន្លែងពិធីក្រែងឃើញតរុណី.....តែសល់តែក្រុមអ្នករៀបចំកម្មវិធី កំពុងចាត់ចែង
បោសសម្អាតនិងរៀបចំតុកៅអី ខ្ញុំក៏ដើរតយង៉យ វិលត្រលប់ក្រោយវិញ។
ស្លឹកឈើបៃតងស្រងាត់នៅលើដើមឈើ បោកបក់តាមកម្លាំងខ្យល់ដ៏ខ្លាំងនាយប់អធ្រាត្រនេះ ញាំងឱ្យ
អ្នកគ្មានអាវវែងដូចខ្ញុំ ស្រៀវរងាបានភ្លាមៗ។
ខ្ញុំគួរតែដេកលក់ល្អជាងរត់បកចុះឡើងបែបនេះ ប៉ុន្តែតាមពិតវាជាចរិតអ្នកសារព័ត៌មានដូចខ្ញុំដែល
តែងចង់ដឹងនិងសង្ស័យច្រើន។
គុម្ពោតព្រៃនៅរប៉េះរប៉ោះតាមផ្លូវ ឯភ្លើងកន្លែងខ្លះភ្លឺ ទីខ្លះងងឹតជារឿងធម្មតា។
មិនបានសូម្បីតែឃើញអ្នកមកពីភ្នំពេញណាផ្សេងម្នាក់សោះ ប្រហែលមកពីថ្ងៃនេះសម្រុកសរសេរអត្ថ
បទច្រើនពេក មិនដឹងមានភ្ញៀវដូចខ្ញុំគេងក្បែរៗនេះដែរឬអត់ទេ?

ផ្គរគ្រហឹម....ប្រសិនបើភ្លៀងធ្លាក់មុនរដូវ អ្វីដែលបានប្រុងថានឹងកើតឡើង អាចនឹងប្តូរខ្លះ ឬមិនអាចកើតឡើងបានតែម្តង ដោយសារគំនូរខ្លះមិនអាចទទឹកបានទេ ឯចំនួនគំនូរដែលបានដាក់មកតាំងហាក់ច្រើនជាងទំហំសាល។

«ឈប់!»

ស្មានតែហៅខ្ញុំ!

ជើងខ្ញុំឈប់ផ្ទឹង ខណៈនោះជាសម្លឹងសម្លុតរបស់មនុស្សប្រុសចំណាស់ហាក់កាចៗ។

មនុស្សម្នាក់រត់កាត់រឹងពីមុខខ្ញុំ។

ឃើញភ្លាម មួយប៉ប្រិចភ្នែកក៏ស្គាល់ថា«នាង»ដែរ។

«តរុណី»

ខ្ញុំប្រាប់ខ្លួនឯងតិចៗ ប្រុងថានឹងរត់ទៅតាមនាងស្រាប់តែម្ចាស់សំឡេងគំហកនោះប្រដេញមកដល់ហើយហួសផុតពីភ្នែកខ្ញុំទៅ។

ស្អីអីចេះ? ខ្លួនជាប្រុស រំលងអធ្រាត្រថ្មើរណេះប្រដេញជាមួយមនុស្សស្រី?

ខ្ញុំរត់តាម ប៉ុន្តែពួកគេលឿនណាស់ បាត់សូន្យទៅក្នុងធម្មជាតិ។

ខ្ញុំនៅឆ្លេឆ្លាម្នាក់ឯងក្នុងស្បែរាត្រីមួយសន្ទុះធំហើយនៅតែមិនឃើញនាងឬតម្រុយអំពីអ្វីដែលបានឃើញចម្លែកៗ ក៏បានងាកមករកបន្ទប់របស់ខ្ញុំវិញក្រោយពីស្វាបហមៗ។

ចូលអង្គុយនៅតុមិនទាន់ដោះស្បែកជើងចប់ស្រួលផង ខ្ញុំភ្ញាក់របូតស្បែកជើងពីដៃ ព្រោះសម្លឹងមើលទៅក្រៅបង្អួចដែលទល់មុខនឹងតុនេះ ខ្ញុំឃើញស្រមោលមនុស្សឈរ។

ទាញវាំងននបើកខ្វាកទាំងភ័យសឹងគាំងបេះដូង....ខ្ញុំឃើញនាង.....

«តរុណី?»

មិននឹកស្មានថា មុននេះទើបនឹងបានឃើញនាងត្រូវគេប្រដេញមក ពេលឥឡូវនាងមកធ្វើហត់គយូសទឹកមុខស្លេកស្លាំង ភ្នែកទាំងសងរូងជ្រៅភ័យបារម្ភហើយមកពួនចាំខ្ញុំក្រៅបង្អួចហ្នឹងសោះ?

ស្រីនិងប្រុស ជួបគ្នារាត្រីស្ងាត់ស្ងើរណេះ វាមិនសមរម្យណាស់ទៅហើយ ចុះទម្រាំបើខ្ញុំបើកទ្វារហៅនាងចូលមកនិយាយគ្នា?

ទោះយ៉ាងណា រឿងនេះពិតជាបានកើតឡើង....យើងមិនអាចទៅឈរនិយាយគ្នានៅឯក្រៅហ្នឹងហើយដឹងរឿងហេតុដែលនាងត្រូវមនុស្សប្រុសតាមប្រដេញមកនោះទេ។

ដៃនាងមានពិលដ៏ធំមួយតែមិនបានបើកវាប្រើឡើយ....

ខ្ញុំស៊ីញ៉ូឱ្យនាងចូលមកក្នុង ដោយពីរនាក់យើងមិនទាន់និយាយអ្វីមួយអឺះណាទាំងអស់ ខ្លាចមានគេនៅក្បែរនេះលួចស្តាប់ឮ។

ខ្ញុំសម្លឹងជុំវិញបន្ទប់ឱ្យច្បាស់ថាគ្មានគេតាមមកសិន មុនពេលបិទទ្វារមកវិញ ហើយងាកមកខ្សឹបសួរនាង ភ្លាមដោយអន្ទះសារ៖

«មុននេះមានរឿងអី?!»

នាងលើកដបទឹកមួយមកមួលផឹកក្អឹកមិនសុំខ្ញុំទេ ។ អាការៈបង្ហាញថា នាងហេវហត់និងជួបរឿងមិនល្អពិតណាស់។

«ខ្ញុំហត់ពេក ពេលគេកំពុងធ្វើពិធីបើក ក៏ឆ្លៀតបកទៅគេងសម្រាកបន្តិចកាលពីព្រលប់! បិទភ្នែកភ្លាមខ្ញុំឮសំឡេងមនុស្សប្រុសដដែលស្រែកឱ្យជួយ! ខ្ញុំអន្ទះសារខ្លាំងមិនដឹងរកទ្វារឯងយ៉ាងម៉េច ក៏ចេញមកខាងក្រៅផ្ទះសំណាក់ ថាមកកន្លែងនេះ ចៃដន្យខ្ញុំឃើញមីងចុងភៅនោះ ឱបអ្វីមួយធំ ដូចជាក្បាលមនុស្ស! ខ្ញុំឃើញសក់ .....និងស្នាមដានឈាម»

សារជាថ្មី ខ្ញុំសឹងរបូតទូរសព្ទពីដៃដែលបម្រុងថាSAVEលេខនាងទុក និងឱ្យលេខរបស់ខ្ញុំទៅនាង។ ចិត្តពេលនេះហោះហើរស្រមៃដល់មនុស្សបួននាក់ ដែលខ្ញុំទើបនឹងបានឃើញដើរផងរត់ផងញាប់ស្មេរចេញពីច្រកហាមឃាត់។ មនុស្សស្រីចំណាស់ម្នាក់នោះ និងមីងចុងភៅដែលនាងទើបនឹងរម្លឹក មិនដឹងថាជាមនុស្សតែម្នាក់ឬអីទេ តែគាត់ពិតជាបានឱបរបស់អ្វីមួយរត់រលះរលាំងមែន។

យ៉ាងណាក៏ដោយ ម៉ោងថ្មើរណេះហើយនិយាយរឿងបែបនេះមិនសមទេ.....ខ្ញុំហាក់ស្ទាក់ស្ទើរក្នុងការសម្រេចចិត្តនិយាយ......

«អង្គុយបាត់ហត់សិនទៅ! ចាំខ្ញុំជូនទៅបន្ទប់វិញ......!»

នាងដាក់កែវចុះភ្លាមនិងគ្រវីក្បាលដូចមនុស្សតក់ក្រហល់ភ័យ។

«យើងប្ដឹងប៉ូលិសទៅ!ពួកនៅផ្ទះសំណាក់នោះចម្លែកៗណាស់!»

ខ្ញុំងក់ក្បាលពេលឃើញនាងភ័យខ្លាំងពេក។ នេះមិនមែនជារឿងលេងសើចទេ។ ខ្ញុំស្ទើរតែនិយាយនូវអ្វីដែលខ្ញុំទើបនឹងបានឃើញនៅឯច្រកហាមឃាត់ដល់នាង តែមកនឹកឃើញភ្លាមថា បានត្រឹមបង្កើតការភ័យខ្លាចដល់នាង ក៏សង្កត់ចិត្តវិញមិននិយាយ។

«យ៉ាងហោចណាស់យើងចាំស្ទាត់បន្តិចចេញទៅខេត្តឥឡូវនេះឱ្យគេមកស៊ើបមីងនោះនិងពួកសន្តិសុខ!»នាងថាខ្សឹបៗ ស្រាប់តែស្នូរជើងជាច្រើនរត់មកដល់។

នាងបើកភ្នែកធំៗ ភ្នែកភ័យនៅកញ្ជឹងក។

«មកតាមណេះច្បាស់ណាស់!ស្រាប់តែបាត់ឈឹងនៀក!»

ពួកគេតាមនាងមកខ្ញុំដឹង។ ចំណែកនាងក៏ស្ទុះក្រោកឡើង លែងអង្គុយនឹងព្រោះតែនៅមិនសុខ។ បន្ទប់យើងនៅបើកភ្លើង នៅឡើយ នឹងចុចបិទក៏ហួសពេលដែរ ព្រោះនោះគឺជាការសារភាពថាយើងដឹងរឿងដែលពួកគេតាមរកនាងកណ្ដាលយប់។

«ពួន!»

ខ្ញុំខ្សឹបខ្សៀ ហើយរំពៃរកកន្លែង។ បន្ទប់ទឹក ពួនទៅមិនរួចទេប្រសិនពួកគេចូលមកមែន។ គ្រែក៏មិនមានថតក្រោមចំហ ម្លោះហើយខ្ញុំស៊ីញ៉ូឱ្យនាងទៅឈរក្រោយទ្វារ ។

នាងដូចយល់ច្បាស់ក្រោកទៅភ្លាម។

ខ្ញុំអង្គុយចុះ ធ្វើនិងចុចបើកlaptop។

សម្រឹបជើងលាន់មកកៀក ហើយស្នូរគោះបន្ទប់ចាប់ផ្តើមឡើងដោយមិនបង្អង់ទេ ប៉ុន្តែគោះតិចៗ.....

«អ្នកណា?»

ខ្ញុំធ្វើជាសួរពន្យារពេលដោយ បើករកអត្ថបទមួយមកបំភាន់លើអេក្រង់ជាមុនសិន ខណៈនៅខាងក្រៅឮសំឡេងសួរមកសុភាពៗ៖

«អត់ទោសលោកក្មួយនៅនៅមិនទាន់សម្រាន្តទេ?!»

«ខ្ញុំជិតរួចដៃហើយ!»

«សរសេរអត្ថបទមែនទេ?!»

ដឹងច្បាស់មែនថានេះជាបន្ទប់គេងរបស់ខ្ញុំ ដែលជាអ្នកសារព័ត៌មានកំពុងសរសេរអត្ថបទទៀត?

«ខ្ញុំសុំនិយាយនឹងលោកក្មួយបន្តិចបានទេ?»

ខ្ញុំក្រោកបើកទ្វារព្រោះបានត្រៀមរួចហើយ។

មនុស្សប្រុសបីនាក់ ដែលខ្ញុំបានឃើញឆ្លេឆ្លានៅច្រកទ្វារហាមឃាត់ បានប្រាកដប្រាណនៅទីនេះ ហើយព្យាយាមសម្លឹងមកក្នុងបន្ទប់នេះហាក់អន្ទះសារណាស់។

«មានរឿងអី?!»

ខ្ញុំស្វាបផងសួរផងធ្វើមីងមាំង។

«អត់អីទេ ខ្ញុំដើរឆែកសុវត្ថិភាពភ្ញៀវ!»

ពួកគេប្រាកដណាស់ថា មិនហ៊ាននិយាយរឿងវិចិត្រករស្រីបាត់ខ្លួន ថែមទាំងមិនហ៊ានទារឆែកទៀត ព្រោះនេះអាចស្មើន័យថា«មិនទុកចិត្តក្រមសីលធម៌ភ្ញៀវ។»

«ម៉េចក៏ម្តុំនេះស្ងាត់ម្លេះ ? បន្ទប់អស់នោះមានគេសម្រាន្តដែរ?!»

ខ្ញុំធ្វើជាសួរកំដរពេលបារម្ភ។ ម្នាក់ក្នុងចំណោមពួកគេឆ្លើយឡើង៖

«បន្ទប់ជួរនេះ VIP រៀបចំទុកសម្រាប់ខាងខេត្តដែរ! តែមិនដឹងម៉េច ពួកគាត់មិនចូលសម្រាន្ត ហូបរួចឃើញចេញឡានទៅវិញអស់!»

«គ្មានអ្នកណាហ៊ានដេកកន្លែងចម្លែកបែបហ្នឹងទេ!»ខ្ញុំគិតម្នាក់ឯងក្នុងចិត្ត តែមិននិយាយគិតពីញញឹម។

«អញ្ជើញសម្រាន្ត! ម៉ោងជាងមួយហើយ!»

«បាទ! ហើយ.....បងៗវិញ....ដើរយាមដល់ពេលណានៀក?»

«អត់ទេ! ពួកខ្ញុំក៏រកចូលសម្រាកដែរ បើគ្មានអីកើតឡើងនោះ!»
ពួកគេនិយាយមិនពិតទេខ្ញុំយល់។ គេតាមរកនាងទេតើ ប៉ុន្តែតើរកព្រោះមូលហេតុអ្វី?
ទោះយ៉ាងណា រវាងនាងនឹងពួកគេ ខ្ញុំឃើញថា នាងនិយាយស្ដីស្មោះត្រង់ជាង ឯពួកគេវិញ មានគ្នាច្រើនហើយធ្វើចរិតប្លែកៗយប់ឡើងរត់ចច្រប់ ផែកគោះបន្ទប់ភ្ញៀវ និយាយស្ដីចេះរួមគ្នាកុហកយ៉ាងប៉ុនទៀត?
ខ្ញុំបិទទ្វារគ្រឹបវិញ ទាំងធូរទ្រូងខ្យាកព្រោះ ទីបំផុតពួកគេត្រូវថយចេញទៅវិញស្ងាត់ៗ។ មធ្យោបាយបន្ទាប់ គឺចុចភ្លើងបិទ។
យើងទាំងពីរមិនហ៊ាននិយាយគ្នាទេ ដ្បិតនាងនៅឈរសំកាំងកន្លៀតជញ្ជាំងនោះដដែលឯខ្ញុំអង្គុយសឹងមិនហ៊ានដកដង្ហើមឮនៅក្បែរតុ។
ខ្ញុំសរសេរលើLaptopសួរនាងថា «ពួកគេសង្ស័យទេ?»ហើយបង្វិលទៅឱ្យនាងអាន ។ នាងមិននិយាយដោយស្ទុះទៅក្បែរបង្អួចសម្លឹងពិនិត្យទិដ្ឋភាពខាងក្រៅ។ ខ្ញុំទៅក្បែរដែរ ។ ពីនេះទៅយើងបានឃើញពួកគេចាកចេញមិនមែនបីនាក់ទេគឺបួននាក់។ ស្ត្រីចំណាស់ម្នាក់នោះក៏បានមកជាមួយពួកគេដែរ គ្រាន់តែមិនបង្ហាញខ្លួននៅនឹងមុខទ្វារបន្ទប់ខ្ញុំមុននេះ។
«យើងចាំបន្តិច សឹមទៅកន្លែងនោះ!»
នាងខ្សឹបៗដោយមិនងាកមកទេ ព្រោះភ្នែកផ្ដោតតែសម្លឹងទៅពួកអ្នកទាំងនោះនៅខាងក្រៅរហូតបាំងបាត់ក្នុងស្បៃរាត្រី។
«កន្លែងណា? ម៉ោងជិតពីរភ្លឺហើយ មិនសម្រាកទេ!» នេះគឺខ្ញុំខ្សឹបសួរវិញ។
«គេងមិនលក់ទេពុទ្ធា! កន្លែងនេះ មានអ្វីម្យ៉ាងចម្លែកៗឡើងៗ ខ្ញុំសង្ស័យណាស់!»
តរុណីក៏ងាកមកវិញ សម្លឹងខ្ញុំក្នុងសភាពងងឹតហើយខ្សឹបខ្សៀវទៀត៖
«ដឹងទេ? យប់មិញនេះខ្ញុំគេងមិនលក់សោះ គឺមិនលក់មួយយប់ទល់ភ្លឺ!»
«ខ្ញុំដឹង! ភ្នែករបស់តរុណីរូងខ្លាំងណាស់ !»
«ត្រូវហើយ! ខ្ញុំឮសូរមនុស្សស្រែកឱ្យជួយរហូត គឺខ្ញុំឮសូរពេញខួរក្បាលរបស់ខ្ញុំពិតមែន! កុំប្រាប់ខ្ញុំវិញថាជាការរវើរវាយអី! ខ្ញុំពិសោធន៍រួចហើយនៅផ្លូវងងឹតខាងក្រោយនោះអាចមានកន្លែងដាក់អ្នករបួស!»
ខ្ញុំនៅចំហមាត់ស្ដុងស្ដាប់នាង។ នាងខ្សឹបពន្យល់ខ្ញុំ៖
«ទោះបីស្ថិតក្នុងអាកាសធាតុត្រជាក់ខ្លាំងក៏ដោយគ្មានមនុស្សណាឃើញហើយថ្ងូរមិនឈប់ទេ! ខ្ញុំដំបូងឡើយស្មានថាមីងចុងភៅនោះជាមនុស្សល្អទៅពិគ្រោះជាមួយគាត់ស្រាប់តែបាត់ឮសំឡេងស្រែកហើយខ្ញុំឃើញគាត់ដឹកនាំប្រុសៗមាឌធំបីនាក់ដើររ៉េវចេញចូលចុះឡើងផ្លូវដែលងងឹតគ្មានអ្នកណា

ទៅ! ពុទ្ធាឯងគិតមើល ហេតុអីក៏នៅណោះ បែរជានៅមានកន្លែងងងឹតៗ ហើយម្ចាស់Event មិនព្រម លៃលកដាក់អំពូលបំភ្លឺខ្លះ?!»

«ចង់ថា....!»

នាងងក់ក្បាល៖

«សាស្ត្រាចារ្យ ជា បណ្ឌិតម្នាក់នេះ ពិតជាគួរឱ្យសង្ស័យបំផុត! គាត់អាចជាមេក្លោងទេពុទ្ធា? »

«មេ....មេក្លោងរឿងអី?!»

«គាត់....គាត់មើលខ្ញុំចម្លែកៗ! ខ្ញុំទទួលអារម្មណ៍មិនធម្មតានេះតាំងពីពេលមកដល់កាលម្សិលមិញ ភ្លាម! ដឹងអត់ គំនូរខ្ញុំជាងម្ភៃសន្លឹកគាត់ឱ្យកូនចៅគាត់មកថតយកទៅទាំងអស់ មិនដឹងមានបំណងអី ឬ ពិនិត្យរឿងអីទេ?»

ខ្ញុំនៅផ្ទឹងនិយាយហាក់មិនមានគោលដៅច្បាស់៖

«មិនដឹងទេ តែ ពេលព្រឹកមិញមកដល់ ឃើញគាត់និយាយរឿងឈាមមនុស្សលាយថ្នាំអីនោះ ខ្ញុំមិន ដែលឮសោះ ពេលឃើញគាត់ថាអ៊ីចឹងមក រាងមានអារម្មណ៍ប្លែកដែរ និយាយមែន!!»

នាងងាកមុខចេញពេលឮអំពីរឿងយកឈាមមកលាយថ្នាំគូរគំនូរ។ ខ្ញុំក៏និយាយបន្តខ្សាវៗ៖

«យើងជាវិចិត្រករដែរ ដែលឮអត់ រឿងគំនូរឈាមអីហ្នឹង!»

វិចិត្រករទ្រោបក្បាលហាក់ទន់ ឬឈឺមួយរំពេច។ ប្រហែលពាក្យឈាមរំញោចចិត្តនាងឬនាងហត់ ពេក?

«កើតអីហ្នឹង? ថានេះ...សម្រាកបន្តិចទៅ!»

ខ្ញុំនិយាយដោយស្មោះស្រាប់តែនាងរលាស់ដៃខ្ញុំចេញដែលប្រុងទ្រត្រកងខ្លាចក្រែងនាងហត់ពេកដួល ។ សភាពកម្លាំងនាងរហ័សនិងខ្លាំងណាស់បើធៀបនឹងស្ត្រីផ្សេងៗ ។នេះប្រហែលជាប្រតិកម្មដែល នាងអៀន ឬខ្លាច ដោយឃើញយើងនៅក្នុងបន្ទប់ស្ងាត់ៗ ងងឹតៗ តែពីរនាក់ស្រីប្រុសតទល់ ហើយ ប្រទ្បំថា ខ្ញុំចង់កេងចំណេញខិតលើហើយមើលទៅ។

«ខ្ញុំសុំទោស! មកពីខ្ញុំខ្លាចតរុណីវិលមុខដួលទេ! ព្រោះ ឮថាយប់មិញមិនបាន សម្រាកហើយឥឡូវមិន បានសម្រាកទៀត!»

«ម៉េចបានជាពុទ្ធាឯងចាប់អារម្មណ៍រឿងឈាមរឿងអីហ្នឹង?!»

នាងងាកមកសួរខ្ញុំជាមួយពន្លឺភ្នែកមុត។

«អត់ទេ! តែ ....ខ្ញុំពិតជាមិនដឹងថាហេតុអីមកដល់EVENT ចំពេលគេនិយាយអំពីប្រធានបទនេះ!»

«ម៉េចខ្ញុំមិនឮ?»

«ព្រោះពេលហ្នឹង តរុណីជាប់ឆ្លងថ្នល់ទៅជួយមនុស្សចាស់ម្នាក់ ដែលឡានតាក់ស៊ីប្រុងបោលគិន!»

«អូ!»

នាងថាតែប៉ុណ្ណឹងហើយក៏ផ្អែកចង្កេះនឹងតុសរសេរវិញលែងមាត់។
«និយាយរឿងឮសំឡេងមនុស្សស្រែកឱ្យជួយហ្នឹងម្ដង! ជាអ្នកណាទៅ? អាចជាករណីអី? »
«វាដូចជា....អ្នកណាម្នាក់....ត្រូវគេចាប់ ចងជាប់នឹងរបាឬចម្រឹង....ដូចជានរណាម្នាក់ត្រូវបានចាក់សោរនៅក្នុងបន្ទប់ក្រោមដី ឬពន្ធនាគារ .....គុក ....សភាពរបស់គេនៅពេលស្រែក..... ខ្ញុំចាំបានថា....គាត់មានរបួស.....ខ្សោយទៅៗ...ដែលមើលទៅហាក់ដូចជា.....ជិត....ជិតលែងដឹងខ្លួនហើយ....ដៃគាត់....អង្រួនទ្វារ......ហើយក៏ឈប់!»
តរុណីនិយាយវែងៗ ហត់ៗ តែខ្ញុំឯណេះគ្រាន់តែស្តាប់ក៏ហាក់ឃើញរូបភាពដែរ......នាងនិយាយអំពីបុរសម្នាក់នោះត្រូវបានអ្នកណាម្នាក់បង្ខាំងនិងដាក់ទារុណកម្មទៅកាន់គាត់ដោយកាយវិការយ៉ាងព្រៃផ្សៃ .....
ព្រឺខ្លួនហើយ!
ខ្ញុំលើកដៃមកឱបកំដរអាកាសធាតុរងា.... ស្រាប់តែនាងកេះហៅ....
«តោះទៅ!»
ខ្ញុំមីងមាំងមិនដឹងថាទៅណាទេ។